ការិយាល័យផ្នែកការទប់ស្កាត់អំពើហិង្សា របស់នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី LOS ANGELES
(LOS ANGELES COUNTY DEPARTMENT OF PUBLIC HEALTH OFFICE OF VIOLENCE PREVENTION)

# GVROs

## ដីកាហាមឃាត់ផ្នែកអំពើហិង្សាទាក់ទងទៅនឹងកាំភ្លើង

### តើ GVRO គឺជាអ្វី?

ដីកាហាមឃាត់ផ្នែកអំពើហិង្សាទាក់ទងទៅនឹងកាំភ្លើង (Gun Violence Restraining Order/GVRO) អាចបញ្ឈប់បុគ្គលម្នាក់បានពីការមាន ធ្វើជាម្ចាស់ ឬទិញកាំភ្លើង ផ្នែកនៃកាំភ្លើង គ្រាប់កាំភ្លើង ឬក៏បង់កាំភ្លើង។

មន្ត្រីប៉ូលីស សមាជិកក្រុមគ្រួសារ ដៃគូស្នេហា អ្នកស្នាក់នៅក្នុងផ្ទះជាមួយគ្នា ម្ចាស់អាជីវកម្មឬកន្លែងការងារ អ្នកធ្វើការនៅកន្លែងជាមួយគ្នា ហើយនិង មន្ត្រីនៅសាលារៀនគឺអាចទទួលយក GVRO មកប្រើប្រាស់បាន។

GVRO ដកហូតកាំភ្លើង និង/ឬគ្រាប់កាំភ្លើងពីបុគ្គលទាំងឡាយដែលប្រឈមនឹងហានិភ័យនៃការបង្កឱ្យមានគ្រោះថ្នាក់ដល់ខ្លួនពួកគេផ្ទាល់ ឬអ្នកដទៃ សម្រាប់រយៈពេល 21 ថ្ងៃ និងរហូតដល់រយៈពេល 5 ឆ្នាំ។

### តើនរណាខ្លះអាចស្នើសុំ GVRO បាន?

- ☐ សមាជិកក្រុមគ្រួសារ
- ☐ សមាជិករស់នៅក្នុងផ្ទះ ឬអ្នកជួលផ្ទះជាមួយគ្នា
- ☐ ម្ចាស់អាជីវកម្មឬកន្លែងការងារ មិត្តរួមការងារ គ្រូបង្រៀន ឬក៏បុគ្គលិកមួយចំនួននៅតាមសាលារៀន
- ☐ អ្នកដែលមានទំនាក់ទំនងស្នេហា
- ☐ អ្នកដែលមានកូនជាមួយគ្នា
- ☐ មន្ត្រីប៉ូលីស

### ហេតុអ្វីបានជាបុគ្គលម្នាក់ប្រហែលជាត្រូវការ GVRO?

GVRO គឺអាចជាមានប្រយោជន៍ ប្រសិនបើបុគ្គលម្នាក់កំពុងមានវិបត្តិ និងកំពុងបង្ហាញសញ្ញានានាថាពួកគេប្រហែលជាអាចបង្ករបួសស្នាមដល់ខ្លួនពួកគេផ្ទាល់ ឬអ្នកដទៃ។ បុគ្គលម្នាក់ដែលអាចរកកាំភ្លើងមកប្រើប្រាស់បានគឺបង្កើនហានិភ័យនៃការស្លាប់ និងការរងរបួសសម្រាប់ខ្លួនពួកគេផ្ទាល់ និងអ្នកដទៃ។

### តើ GVRO មានមុខងារសម្រាប់ធ្វើអ្វីខ្លះ?

- ដកហូតកាំភ្លើង ឬគ្រាប់កាំភ្លើងពីបុគ្គលទាំងឡាយណាដែលបង្កជាគ្រោះថ្នាក់ដល់ខ្លួនពួកគេផ្ទាល់ ឬអ្នកដទៃ។
- អនុញ្ញាតឱ្យអ្នកដែលត្រូវប្រកាន់ខ្ជាប់ទៅនឹងដីកាហាមឃាត់នោះមានពេលវេលាសម្រាប់ស្វែងរកជំនួយ។
- អនុញាតឱ្យមន្ត្រីប៉ូលីសមានពេលវេលាសម្រាប់ស្វែងរកដីកាហាមឃាត់សម្រាប់រយៈពេលចាប់ពី 1 ទៅ 5 ឆ្នាំ។

### ប្រភេទ GVRO ផ្សេងៗ

- មានតែមន្ត្រីប៉ូលីសទេដែលអាចទទួលយក **GVRO សម្រាប់ការគាំពារក្នុងករណីបន្ទាន់ (Emergency Protective GVRO)** មកប្រើប្រាស់បាន។
- **GVRO បណ្តោះអាសន្ន (Temporary GVRO)** គឺអាចស្នើសុំដោយខ្លួនឯងបាន តាមរយៈការបំពេញ និងការដាក់បញ្ជូនបែបបទរបស់តុលាការដែលតម្រូវចាំបាច់ទាំងអស់។ បែបបទទាំងឡាយគឺមិនគិតថ្លៃឡើយ ហើយអាចរកបានតាមអនឡាញ និងនៅតាមសាលាកាត់ក្តីជាន់ខ្ពស់នៃខោនធី LA (LA County Superior Court) ណាមួយក៏ដោយ។
- GVRO គឺជាឯកសារបណ្តោះអាសន្នមួយ រហូតដល់ពេលចៅក្រមកំណត់ផ្តល់ជូនដីកានេះសម្រាប់រយៈពេលជាក់លាក់មួយ។

### វិធីទទួលយក GVRO មកប្រើប្រាស់៖

1. ក្នុងករណីបន្ទាន់មួយ សូមទូរស័ព្ទទៅកាន់លេខ 911។ មានតែមន្ត្រីប៉ូលីសទេដែលអាចទទួលយក GVRO សម្រាប់ការគាំពារក្នុងករណីបន្ទាន់ (Emergency Protective GVRO) មកប្រើប្រាស់បាន។
2. ចំពោះ GVRO បណ្តោះអាសន្ន (Temporary GVRO) ហើយប្រសិនបើអ្នកគិតថាមិនអីទេនោះ សូមទៅកាន់ស្ថានីយប៉ូលីសនៅក្នុងតំបន់របស់អ្នក ឬសាលាកាត់ក្តីជាន់ខ្ពស់នៃខោនធី Los Angeles (Los Angeles County Superior Courthouse) ណាមួយក៏បាន។ សម្រាប់ព័ត៌មានបន្ថែមអំពីសាលាកាត់ក្តីនានា សូមចូលទៅកាន់គេហទំព័រ៖៖ https://www.lacourt.org/courthouse។
3. ជំនួយគឺអាចរកបានផងដែរ នៅ៖
   - គ្រឹះស្ថានផ្នែកជំនួយផ្លូវច្បាប់នៃទីក្រុង Los Angeles (Legal Aid of Los Angeles) គេហទំព័រ៖ https://lafla.org/
   - សេចក្តីណែនាំសម្រាប់ជាជំនួយដល់ខ្លួនឯងអំពីតុលាការនៃរដ្ឋ California (CA Courts – Self Help Guide) គេហទំព័រ៖ https://selfhelp.courts.ca.gov/GV-restraining-order

### ត្រូវការជំនួយថាគួរតែធ្វើបែបណាចំពោះ GVRO ផ្សេងៗឬ? ការិយាល័យផ្នែកការទប់ស្កាត់អំពើហិង្សា (OVP) គឺអាចជួយបាន។

សូមទាក់ទងទៅកាន់អ្នកផ្តល់ការណែនាំថាគួរតែធ្វើបែបណាចំពោះ GVRO របស់ OVP តាមរយៈ៖

អ៊ីម៉ែល៖ ovp_gvro@ph.lacounty.gov

លេខទូរស័ព្ទ៖ 833.540.0473



**ស្វែងរកឯកសារដែលត្រឹមត្រូវ នៅលើគេហទំព័រ៖ LACountyGVRO.org**

LOS ANGELES COUNTY OVP OFFICE OF VIOLENCE PREVENTION
COUNTY OF LOS ANGELES Public Health
[Cambodian]